# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ រវាង

លោក ម៉ែន ផល្លីន កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៧០៣៧៥៤១៨ ដែលមានតួនាទី **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **ហ្វូដឡាយហ្វ៍ ឯ.ក** ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ២៥ ផ្លូវ៥២៨ កែងផ្លូវ២៨៣ សង្កាត់បឹងកក់១ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

និង

លោក ស៊ិន សារ៉េត កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០៥០៨៥៥៩៥៦ ដែលមានតួនាទីជា **ប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន** និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។

លោក ងួន ប៊ុននី កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១២៦៧៩៩៣ ដែលមានតួនាទីជា **មេផ្នែកចុងភៅ** និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

០១- <u>រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖</u>

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

០២- <u>ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖</u>

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

០៣- <u>កាលបរិច្ឆេទចូលបម្រើការងារវិញ៖</u>

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្សីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០

| តំណាងភាគីនិយោជិក | | តំណាងភាគីនិយោជក |
|---|---|---|
| លោក ស៊ិន សារ៉េត | លោក ងួន ប៊ុននី | លោក ម៉ែន ផល្លីន |